ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការប្រមូលត្រឡប់ពីទីផ្សារ នូវផលិតផលទឹកដោះគោម្សៅ

ក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនដល់សាធារណជន ជាពិសេសមាតាបិតា និងអាណាព្យាបាលទារក និងកុមារទាំងអស់ឱ្យបានជ្រាបថា យោងតាមការផ្សព្វផ្សាយរបស់ទីភ្នាក់ងារសុវត្ថិភាពចំណីអាហារនៃប្រទេសសិង្ហបុរី បានបញ្ជាក់ថាផលិតផលទឹកដោះគោម្សៅ ៥ឡូតិ៍ ដូចមានឈ្មោះក្នុង តារាងទី១ អាចមានវត្ថុមានជាតិពុល Cereulide toxin និងផលិតផលទឹកដោះគោម្សៅ ២ឡូតិ៍ ដូចមានឈ្មោះក្នុង តារាងទី២ មានវត្ថុមានជាតិពុល Cereulide toxin បង្កហានិភ័យដល់សុខភាពទារក កុមារ និងអ្នកប្រើទូទៅផងដែរ៖

តារាងទី១៖

| ល.រ | ឈ្មោះផលិតផលទឹកដោះគោម្សៅ | ទម្ងន់/កំប៉ុង | លេខឡូតិ៍ | ថ្ងៃខែឆ្នាំផុតកំណត់ប្រើ | ប្រទេសផលិត |
|---|---|---|---|---|---|
| ១. | NAN HA 1 SupremePro | ៨០០ក្រាម | 51470017C1 | 31 May 2027 | ស្វីស |
| ២. | NAN HA 1 SupremePro | ៨០០ក្រាម | 51460017C2 | 31 May 2027 | ស្វីស |
| ៣. | NAN HA 2 SupremePro | ៨០០ក្រាម | 51420017C4 | 31 May 2027 | ស្វីស |
| ៤. | NAN HA 3 SupremePro | ៨០០ក្រាម | 53030017C1 | 31 Oct 2027 | ស្វីស |
| ៥. | NAN HA 3 SupremePro | ៣២ក្រាម | 53030017B1 | 31 Oct 2026 | ស្វីស |

តារាងទី២៖

| ល.រ | ឈ្មោះផលិតផលទឹកដោះគោម្សៅ | ទម្ងន់/កំប៉ុង | លេខឡូតិ៍ | ថ្ងៃខែឆ្នាំផុតកំណត់ប្រើ | ប្រទេសផលិត |
|---|---|---|---|---|---|
| ១. | Dumex Dulac Stage 1 | ៨០០ក្រាម | 101575737 | 5 Sept 2027 | ថៃឡង់ដ៍ |
| ២. | Dumex Dulac Stage 2 | ៨០០ក្រាម | 101570779 | 5 Sept 2027 | ថៃឡង់ដ៍ |

សូមបញ្ជាក់ថាផលិតផលទាំង៧ឡូតិ៍ខាងលើ ពុំមាននាំចូលមកប្រទេសកម្ពុជាដោយក្រុមហ៊ុនណាមួយទេ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីធានាបាននូវសុវត្ថិភាពចំពោះអ្នកប្រើប្រាស់ ក្រសួងសុខាភិបាលសូមជម្រាបជូនដល់សាធារណជន មាតាបិតា អាណាព្យាបាល អាជីវករ អាជ្ញាធរ ឬអ្នកពាក់ព័ន្ធថា ក្នុងករណីបងប្អូនបានជួបប្រទះឃើញ ឬកំពុងប្រើប្រាស់ លក់ ចែកចាយនូវផលិតផលខាងលើ ឬឃើញទារកកុមារតូចៗដែលមានជំងឺដោយសារការប្រើប្រាស់ផលិតផលខាងលើ សូមបងប្អូនទំនាក់ទំនងប្រគល់ផលិតផលទាំងនោះ ឬទំនាក់ទំនងព័ត៌មានបន្ថែមមក **នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង នៃក្រសួងសុខាភិបាល** តាមរយៈទូរសព្ទលេខ ០៨៥ ៥៣៨ ០៦៦ ឬ ០១២ ២០៤ ០៦៩ ឬ ០១១ ២៣៤ ៥៩០ ឬ ០១១ ៩៧០ ៣២៥។

អាស្រ័យហេតុនេះ សូមសាធារណជន មាតាបិតា អាណាព្យាបាល អាជីវករ និងអាជ្ញាធរពាក់ព័ន្ធ មេត្តាជ្រាប និងចូលរួមសហការអនុវត្តតាមសេចក្តីប្រកាសព័ត៌មាននេះឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមជូនភ្ជាប់មកជាមួយនូវរូបភាពផលិតផលដូចខាងក្រោម។

ថ្ងៃសុក្រ ៤រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦



អាសយដ្ឋាន៖ ដីឡូតិ៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីម៉ែល៖ info@moh.gov.kh
គេហទំព័រ៖ www.moh.gov.kh
តេឡេក្រាម៖ t.me/MOHCambodia




☞ ស្កេនដើម្បីទទួលព័ត៌មានពី
បណ្តាញសង្គមផ្លូវការរបស់
ក្រសួងសុខាភិបាល


អាសយដ្ឋាន៖ ផ្លូវលេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីមែល៖ info@moh.gov.kh
គេហទំព័រ៖ www.moh.gov.kh
តេឡេក្រាម៖ t.me/MOHCambodia